**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អភិបូជាអធិដ្ឋានពេញមួយយប់នៅកាម៉ែល**
**ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៨**
*សូមទៅ!*

អត្ថបទទី១៖ អម ៧,១០-១៧
ដំណឹងល្អ៖ មថ ៩,១-៨

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ យើងជួបជុំគ្នានៅអារាមកាម៉ែល ដើម្បីអធិដ្ឋានពេញមួយយប់។ យើងសប្បាយចិត្ត មួយឆ្នាំម្តងយើងដឹងថាគ្រីស្តបរិស័ទមួយចំនួនមកសួរសុខទុក្ខបងស្រីផង មកអធិដ្ឋានរួមជាមួយគ្នាផង ហើយជាឱកាសមួយដើម្បីឲ្យព្រះសហគមន៍របស់យើងនឹកឃើញអំពីជីវិតអធិដ្ឋាន។ ព្រះសហគមន៍ ឥតមានក្រុមដែលអធិដ្ឋានយ៉ាងជិតស្និទ្ធជាមួយព្រះជាម្ចាស់ វត្តមានរបស់បងស្រីសម្ងាត់ដែលអធិដ្ឋាន ដោយសារជាតួនាទីរបស់គាត់គឺអធិដ្ឋានមិនចេញទៅណា ដើម្បីភ្ជាប់ជាមួយព្រះជាម្ចាស់ ដើម្បីណែនាំព្រះសហគមន៍របស់យើងបន្តិចម្តងៗកែប្រែចិត្តគំនិត ដើម្បីភ្ជាប់ជាមួយព្រះជាម្ចាស់។ វត្តមានរបស់បងស្រីជាទ្រព្យសម្បត្តិយ៉ាងពិសេស សម្រាប់ព្រះសហគមន៍របស់យើងនៅភូមិភាគភ្នំពេញ។

យប់នេះ យើងអធិដ្ឋានសម្រាប់ការត្រាស់ហៅ ជាឱកាសមួយដើម្បីនឹកឃើញអំពីដំណើរជីវិតរបស់យើងជាមួយព្រះជាម្ចាស់។ ពាក្យ "**ដំណើរ**" យើងត្រូវការមើលរបៀបព្រះយេស៊ូ ជីវិតរបស់ព្រះយេស៊ូជាដំណើរមួយ។ ពីថ្ងៃដែលព្រះយេស៊ូចេញពីស្រុកកាលីឡេ ដើម្បីប្រកាសដំណឹងល្អព្រះយេស៊ូបានចាប់ផ្តើមនៅលើភ្នំ ក្រោយមកព្រះយេស៊ូបានទេសនា ដើម្បីអប់រំមហាជនឲ្យគេភ្ញាក់ស្មារតី។ នៅក្នុងសម្ពន្ធមេត្រីចាស់ បានសរសេរថា៖ "**ចាប់ពីពេលនេះតទៅខ្ញុំណែនាំឲ្យយើងចេះស្រឡាញ់សត្រូវ ខ្ញុំណែនាំឲ្យយើងចេះស្រឡាញ់គ្នាទៅវិញទៅមក ខ្ញុំអញ្ជើញបងប្អូនទៅជាអំបិលទៅជាភ្លើង**"។ នៅពេលព្រះយេស៊ូបានទេសនាអស់ហើយ យើងឃើញព្រះយេស៊ូដើរពីភូមិមួយទៅភូមិមួយ ដើម្បីអនុវត្តតាមអ្វីដែលព្រះយេស៊ូបានទេសនា។ ព្រះយេស៊ូមិនតែទេសនាទូទៅ ព្រះយេស៊ូមិនតែចំភ្លឺព្រះបន្ទូលព្រះយេស៊ូសម្រាប់មនុស្សបច្ចុប្បន្ននេះ ប៉ុន្តែព្រះយេស៊ូបានចាប់ផ្តើមអនុវត្ត។ អនុវត្តដោយប្រមូលអ្នកជំងឺឲ្យបានជាសះស្បើយ អ្នកម្តាយក្មេករបស់លោកសិលា ព្រះយេស៊ូនៅជាមួយខ្មោចដែលចូលចូលនៅក្នុងហ្វូងជ្រូក។ ថ្ងៃនេះយើងឃើញព្រះយេស៊ូនៅជាមួយជន

ពិការ ព្រះយេស៊ូដើរពីភូមិមួយទៅភូមិមួយនិងមហាជនគេមក ដោយសារព្រះយេស៊ូបាន ណែនាំឲ្យគេទទួលជីវិតថ្មី ប៉ុន្តែមិនមែនជីវិតថ្មីដោយសារការព្យាបាលតែប៉ុណ្ណឹង មិនមែន ជីវិតថ្មីដោយសារពីមុនគេខ្វិនជើងតែឥលូវដើរបាន មិនមែនជីវិតថ្មីដោយសារម្តាយក្មេក របស់លោកសិលា មានគ្រុនឥលូវនេះគាត់ជាសះស្បើយហើយ មិនមែនបុរសពីរនាក់ដែល ខ្មោចចូល និងឥលូវនេះលែងមានខ្មោចនៅក្នុងខ្លួន។ ជីវិតថ្មីដោយសារព្រះយេស៊ូណែនាំឲ្យ មនុស្សម្នាក់ដែលភ្ជាប់ជាមួយព្រះយេស៊ូរកឃើញតម្លៃនៃជីវិត រកឃើញអត្ថន័យនៃជីវិត រក ឃើញអ្វីដែលជាទ្រព្យសម្បត្តិនៅក្នុងជីវិតរបស់គាត់។ បើយើងចាប់អារម្មណ៍ស្ត្រីដែលធ្លាក់ ឈាម នាយទាហានដែលបានទូលអង្វរព្រះយេស៊ូឲ្យព្យាបាលអ្នកបម្រើគាត់ ថ្ងៃនេះជាមួយ អ្នកខ្វិន ព្រះយេស៊ូឈ្វេងយល់ពីចិត្តគំនិតរបស់គេ។ ព្រះយេស៊ូណែនាំឲ្យគេទទួលជីវិតថ្មី ដោយសារព្រះយេស៊ូឈ្វេងយល់ជំនឿរបស់អ្នកទាំងនោះ។ ព្រះយេស៊ូចេះមើលអ្វីដែល មាន សេចក្តីត្រូវការ ការទន្ទឹងរង់ចាំ និងសេចក្តីត្រូវការមិនមែនតែមានកម្លាំងសាជាថ្មី ប៉ុន្តែ សេចក្តីត្រូវការគឺព្យាបាលដួងចិត្តយ៉ាងជ្រៅ ដើម្បីទៅជាមនុស្សដ៏ពេញលក្ខណៈ។ ម្តាយ ក្មេករបស់លោកសិលា នៅពេលគាត់ជាហើយ គាត់បំពេញតួនាទីរបស់គាត់ជាមេផ្ទះ ជា ម្ចាស់ផ្ទះដែលទទួលភ្ញៀវយ៉ាងរាក់ទាក់។ ស្ត្រីដែលធ្លាក់ឈាម នៅពេលគាត់ពាល់ព្រះ យេស៊ូ ព្រះយេស៊ូឈ្វេងយល់ជំនឿរបស់គាត់ គាត់ទៅជាស្ត្រីដ៏ពេញលក្ខណៈ។ ១២ឆ្នាំ ដែលគាត់ធ្លាក់ឈាមនៅពេលព្រះយេស៊ូបានព្យាលាគាត់ គាត់មានកម្លាំងថ្មីមែន ប៉ុន្តែជា ពិសេសជាស្រីដ៏ពេញលក្ខណៈ ដែលមានអំណរសប្បាយ ដែលមានកិត្តិយស ដែលមាន មោទនភាពដោយសារទទួលជីវិត។ នៅថ្ងៃនេះមនុស្សខ្វិនក៏ដូចគ្នា មុនព្រះយេស៊ូព្យាបាល គាត់ព្រះយេស៊ូមានព្រះបន្ទូលថា "**កូនអើយ! ចូរក្លាហានឡើង! ខ្ញុំអត់ទោសឲ្យអ្នកបានរួចពី បាបហើយ**"។ ព្រះយេស៊ូលើកលែងទោស ដោយសារព្រះយេស៊ូយល់ថា អ្វីដែលសំខាន់មិន មែនដើរដូចពីមុន ប៉ុន្តែអ្វីដែលសំខាន់គឺព្យាបាលអ្វីដែលមាននៅក្នុងដួងចិត្តរបស់គាត់ ដើម្បី ឲ្យអ្នកខ្វិននេះទៅជាមនុស្សពេញលក្ខណៈ ដើរដោយជើងទាំងពីរពិតមែន ប៉ុន្តែដើរនៅក្នុង ជីវិតលែងខ្មាស លែងភ័យ លែងខ្លាច សូមក្លាហានទៅ! ដោយសារជំនឿ ឥលូវនេះទទួល ជីវិតថ្មី។ ហេតុនេះហើយ ព្រះយេស៊ូណែនាំឲ្យមនុស្សម្នាក់អាចបំពេញតួនាទីរបស់គាត់ ផ្ទាល់នៅលើផែនដីនេះ។

លោកអាម៉ូស គាត់និយាយថា "**ខ្ញុំមិនមែនជាព្យាការី ឬជាសមាជិកក្រុមព្យាការី ខ្ញុំជាអ្នកឃ្វាលគោ និងជាអ្នកចម្ការ**" ខ្ញុំអត់មានគំនិតទៅជាព្យាការី ខ្ញុំអត់មានថ្លែងព្រះបន្ទូលដើម្បីឲ្យប្រជារាស្ត្រស្តាប់ឮ និងស្គាល់ព្រះហឫទ័យរបស់ព្រះជាម្ចាស់ទេ ក៏ប៉ុន្តែព្រះអម្ចាស់យកខ្ញុំពីក្រោយហ្វូងគោ ហើយមានព្រះបន្ទូលមកខ្ញុំថា "**ទៅ! ចូរនាំពាក្យយើងទៅថ្លែងប្រាប់អ៊ីស្រាអែលជាប្រជារាស្ត្ររបស់យើងនៅក្នុងនាមយើង**" ព្រះយេស៊ូជ្រើសរើស ដោយសារព្រះយេស៊ូឈ្វេងយល់។ ទោះបីយើងផ្ទាល់ខ្លួនក៏មិនដឹង ក៏ប៉ុន្តែយើងមានសេចក្តីសង្ឃឹមមួយ យើងមានសេចក្តីត្រូវការមួយ យើងមានការស្រេកឃ្លានមួយ ដែលណែនាំឲ្យព្រះយេស៊ូអាចចូលបាននៅក្នុងខ្លួនយើង ដើម្បីឲ្យយើងភ្ញាក់ស្មារតី ឲ្យយើងទទួលស្គាល់អំពីតួនាទី និងការត្រាស់ហៅរបស់យើងនៅក្នុងព្រះសហគមន៍ នៅក្នុងពិភពលោក។ យើងជាបូជាចារ្យ យើងជាបងស្រី យើងដឹងថានៅថ្ងៃដែលព្រះយេស៊ូបានជ្រើសរើសយើង ព្រះយេស៊ូបានយាងចូលនៅក្នុងទ្វារដែលយើងបើកឲ្យព្រះយេស៊ូ។ ព្រះយេស៊ូឈ្វេងយល់សេចក្តីត្រូវការ ឈ្វេងយល់សមត្ថភាពរបស់យើង។

យើងជាអ្នកដឹកនាំ ជាបុរសក្តី ជាស្ត្រីក្តីមិនសំខាន់ទេ អ្វីដែលសំខាន់ អ្នកដឹកនាំជាមនុស្សម្នាក់ដែលណែនាំឲ្យអ្នកដែលខ្លួនដឹកនាំអាចឈរឡើង ដើម្បីបំពេញអស់ពីសមត្ថភាពផ្ទាល់ខ្លួន និងលើសពីអ្វីដែលគាត់ស្មានថាអាចធ្វើបាន។ ព្រះយេស៊ូ ណែនាំឲ្យយើងរៀងៗខ្លួនរកឃើញសមត្ថភាពផ្ទាល់ខ្លួន និងសមត្ថភាពនេះជាសមត្ថភាពយ៉ាងពិសេស ដែលព្រះយេស៊ូប្រើ ដើម្បីឲ្យយើងទៅជាអ្នកបម្រើនៅកន្លែងដែលព្រះយេស៊ូចង់ឲ្យយើងនៅ ដើម្បីធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ដូច្នេះយើងត្រូវតែគិត ជួនកាលយើងវង្វេងនៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ នៅក្នុងការត្រាស់ហៅរបស់យើង ប៉ុន្តែព្រះយេស៊ូឈ្វេងយល់សេចក្តីត្រូវការ ព្រះយេស៊ូឈ្វេងយល់សមត្ថភាពរបស់យើង និងព្រះយេស៊ូណែនាំឲ្យសមត្ថភាពរបស់យើងផ្ទាល់រីកចម្រើន ដើម្បីឲ្យពោរពេញដោយសេចក្តីស្រឡាញ់មកពីព្រះជាម្ចាស់ ឲ្យយើងទៅជាអ្នកបម្រើ ឲ្យយើងទៅជាព្យាការី ឲ្យយើងទៅជាអ្នកដឹកនាំ ឲ្យយើងទៅជាអ្នកជួយលើកទឹកចិត្តបងប្អូនឯទៀតៗ ឲ្យបំពេញការត្រាស់ហៅដូចយើង។

នៅពេលយើងបានស្តាប់ឮព្រះបន្ទូលរបស់ព្រះជាម្ចាស់ សម្រាប់ជីវិតរបស់យើងផ្ទាល់ ព្រះយេស៊ូមានពាក្យនេះ "ទៅ! ចូរនាំពាក្យយើងទៅថ្លៃប្រាប់..." ទៅ! ដូចព្រះយេស៊ូ។ ព្រះយេស៊ូអត់បានអង្គុយលើភ្នំជាប់បីឆ្នាំដើម្បីទេសនា និងពន្យល់ ដើម្បីស្តាប់ និងពន្យល់គេ

ឲ្យធ្វើនេះធ្វើនោះនៅពេលវេលាខ្លី ព្រះយេស៊ូបានទេសនាមួយភ្លែត និងក្រោយមកព្រះយេស៊ូបានទៅ។ ចាប់ផ្ដើមដើរពីភូមិមួយទៅភូមិមួយ ដើម្បីឲ្យសេចក្ដីត្រូវការរបស់មនុស្សម្នាក់ទៅជាកម្លាំងថ្មី និងណែនាំឲ្យមនុស្សម្នាក់រីកចម្រើន។ ស្ត្រីម្នាក់ដែលធ្លាក់ឈាម១២ឆ្នាំនៅថ្ងៃនោះមានមហាជនយ៉ាងច្រើននៅជុំវិញព្រះយេស៊ូ មានច្រើននាក់ដែលថ្ងៃនោះពាល់អាវព្រះយេស៊ូ ស្ត្រីនោះគាត់ភ័យ និងមិនហ៊ានជួបព្រះយេស៊ូពីខាងមុខ ដូច្នេះទើបគាត់ទៅពាល់អាវព្រះយេស៊ូពីខាងក្រោយ តែព្រះយេស៊ូដឹង។ ព្រះយេស៊ូដឹង ដោយសារព្រះយេស៊ូឈ្វេងយល់ អត់ត្រូវការមើលឃើញមុខគាត់ ប៉ុន្តែព្រះយេស៊ូដឹង នៅពេលនោះមានមនុស្សម្នាក់នៅជិតខ្ញុំដែលត្រូវការជីវិត ដែលត្រូវការកម្លាំងថ្មី និងព្រះយេស៊ូណែនាំឲ្យគាត់ជាសះស្បើយ ដោយមានព្រះបន្ទូលថា "**ជំនឿរបស់នាង បានឲ្យនាងជាហើយ សូមទៅ!**"។ សូមទៅកុំឈរ កុំដេក កុំអង្គុយ សូមទៅ! ការត្រាស់ហៅរបស់ព្រះជាម្ចាស់ គឺណែនាំឲ្យយើងយល់ថាព្រះជាម្ចាស់ស្គាល់យើងច្បាស់ណាស់ ព្រះជាម្ចាស់មើលឃើញយើងច្បាស់ណាស់ ទោះបីយើងទៅពាល់ព្រះយេស៊ូពីខាងក្រោយ ដោយសារយើងខ្លាចព្រះយេស៊ូ តែព្រះយេស៊ូយល់ ព្រះយេស៊ូដឹង និងព្រះយេស៊ូចាប់អារម្មណ៍អំពីយើង អំពីម្នាក់ៗដើម្បីឲ្យយើងទទួលជីវិត ដោយសារព្រះយេស៊ូយាងមកដើម្បីឲ្យយើងមានជីវិត។ នៅពេលយើងឆ្លើយតបការត្រាស់ហៅរបស់ព្រះជាម្ចាស់ យើងដឹងថានៅពេលនោះយើងពោរពេញដោយជីវិត។

បងស្រី បានឆ្លើយតបការត្រាស់ហៅរបស់ព្រះជាម្ចាស់ ពោរពេញដោយជីវិតនៅក្នុងអារាម មានមនុស្សច្រើនមិនយល់។ ពិតមែនការត្រាស់ហៅរបស់យើងខុសៗគ្នា ប៉ុន្តែការត្រាស់ហៅហ្នឹង ណែនាំឲ្យយើងពោរពេញដោយអំណរសប្បាយ។ យើងសប្បាយចិត្តដោយសារ យើងមានយុវនារីម្នាក់កំពុងស្វែងយល់ថែមទៀតអំពីការត្រាស់ហៅធ្វើជាបងស្រីសម្ងាត់។ យើងសង្ឃឹមថ្ងៃនេះយើងមានយុវនារីខ្លះៗ បងស្រីដុនបូស្កូយកចិត្តទុកដាក់ដើម្បីឲ្យយុវនារីចូលអធិដ្ឋានជាមួយយើង។ យប់នេះយើងអធិដ្ឋាននៅក្នុងភាពសម្ងាត់ ប្រហែលមានម្នាក់ដែលថាចង់នៅជាមួយបងស្រីសម្ងាត់ថែមទៀត ដោយសារព្រះជាម្ចាស់ត្រាស់ហៅ និងព្រះជាម្ចាស់មានព្រះបន្ទូលថា "**សូមទៅ!**"។ បងស្រីដើររបៀបផ្សេង ដើរនៅក្នុងដួងចិត្ត ហើយនេះជារបៀបមួយយ៉ាងពិសេសបំផុត ដែលនៅក្នុងអារាមកាមែលពីយ៉ូហាននៃឈើឆ្កាង សន្ដីតេរេសាធំ សន្ដីតេរេសាតូច បានណែនាំឲ្យយើងធ្វើដំណើរនៅក្នុងដួងចិត្តរបស់យើងជាមួយព្រះយេស៊ូ ដើម្បីជិតស្និទ្ធជាមួយព្រះយេស៊ូបំផុត និងរកឃើញអំណរសប្បាយ

នៅក្នុងភាពជិតស្និទ្ធហ្នឹង ដោយធ្វើដំណើរនៅក្នុងដួងចិត្តពីមួយថ្ងៃទៅមួយថ្ងៃ។ ខ្ញុំជឿថា អស់មួយជីវិត យើងអត់ទាន់ធ្វើដំណើរអស់នៅក្នុងដួងចិត្តរបស់យើង ទោះបីយើងមានអារម្មណ៍ថាដួងចិត្តមានទំហំតូច ប៉ុន្តែដើម្បីធ្វើដំណើរយ៉ាងជ្រៅនៅក្នុងដួងចិត្ត មួយជីវិតអត់ល្មមទេ។ ប៉ុន្តែបានចាប់ផ្តើមហើយ ដើម្បីឲ្យយើងរៀងៗខ្លួនបានដើរទៅណាទៅណីអាចចូលនៅក្នុងដួងចិត្តរបស់យើងដែរ ដោយសារការអធិដ្ឋាន និងការប្រកាសដំណឹងល្អត្រូវតែធ្វើដំណើរជាមួយគ្នាជានិច្ច។ យើងអត់មានកម្លាំងដើម្បីប្រកាសដំណឹងល្អ ប្រសិនបើយើងមិនរកឃើញប្រភពនៃជីវិតនៅក្នុងព្រះយេស៊ូជាព្រះគ្រីស្ត។ យើងរកឃើញប្រភពនៃជីវិតនៅក្នុងព្រះយេស៊ូជាព្រះគ្រីស្ត នៅក្នុងភាពសម្ងាត់នៅក្នុងការអធិដ្ឋាននៅក្នុងជីវិតយើង។

ដូច្នេះថ្ងៃនេះយើងអរព្រះគុណព្រះជាម្ចាស់ យើងបើកត្រចៀករបស់យើង ឥលូវនេះយើងមានClinicថ្មី សម្រាប់ត្រចៀក ខ្ញុំបានដាក់ឈ្មោះ សន្តប៊ឺន័រ ដោយសារ សន្តប៊ឺន័រ ជាលោកឪពុកដែលបង្កើតអារាមបេនេឌិក និងអារាមសម្ងាត់មុនគេបង្អស់ និងគាត់បានសរសេរនៅក្នុងធម្មនុញ្ញរបស់គាត់ មាត្រា១ **"អ៊ីស្រាអែល សូមស្តាប់!"** ពេលគេគូររូបរបស់គាត់ គេដាក់ត្រចៀកមួយយ៉ាងធំ ដោយសារគាត់ណែនាំឲ្យយើងស្តាប់ព្រះបន្ទូលព្រះជាម្ចាស់។ ដូច្នេះឲ្យយើងបើកត្រចៀករបស់យើងយ៉ាងធំបំផុត ដើម្បីស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដោយដឹងថាព្រះជាម្ចាស់មិនស្រែក ព្រះជាម្ចាស់និយាយខ្សឹបៗ ស្ងាត់ៗ នៅក្នុងខ្យល់ស្រាលៗវត្តមានរបស់ព្រះជាម្ចាស់នៅកន្លែងហ្នឹង។ បងស្រីនៅទីនេះ ដោយសារគាត់ថានៅកន្លែងនេះស្ងាត់ណាស់គាត់ចង់នៅឆ្ងាយពីទីក្រុង ប៉ុន្តែឥលូវនេះជនបទមិនសូវស្ងាត់ទេ ដោយសារពីរដូវមួយទៅរដូវមួយមានបុណ្យកឋិន មានបុណ្យចូលឆ្នាំ មានបុណ្យផ្សេងៗ មានអាពាហ៍ពិពាហ៍ មិនខ្វះអីសោះដើម្បីឲ្យឮសំឡេងជុំវិញ។ ប៉ុន្តែទោះបីយើងឮសំឡេងជុំវិញយើងធ្វើយ៉ាងម៉េចដើម្បីចូលយ៉ាងជ្រៅ ដើម្បីស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលថ្ងៃនេះសម្រាប់ម្នាក់ៗមានព្រះបន្ទូលថា **"ព្រះអម្ចាស់បានជ្រើសរើសខ្ញុំ"** និងព្រះយេស៊ូមានព្រះបន្ទូលថា "**សូមទៅ! ចូរនាំពាក្យយើងទៅថ្លែងប្រាប់ដល់ប្រទេសកម្ពុជាទាំងមូល**"។ អាម៉ែន៕